# ព្រះសង្ឃ និងសិទ្ធិចូលរួមក្នុងការបោះឆ្នោត

ការចូលរួមរបស់ព្រះសង្ឃខ្មែរ ក្នុងវិស័យនយោបាយ សេដ្ឋកិច្ច និងសង្គមបានប្រព្រឹត្តទៅជាហូរហែរតាំងពីកម្ពុជាបានប្រតិបត្តិតាមព្រះពុទ្ធសាសនា និងដោយឡែក មានដូចជាសកម្មភាពចូលរួមក្នុងចលនានយោបាយទាមទារឯករាជ្យពីអាណានិគមបារាំង "សង្គ្រាមឆ័ត្រ" ជាដើម ។

ប៉ុន្តែសព្វថ្ងៃនេះ មានការពិភាក្សាអំពីម្រិតអព្យាក្រិតភាពតាមផ្លូវពុទ្ធសាសនា ទៅនឹងការចូលរួមរបស់ព្រះសង្ឃក្នុងសកម្មភាពនយោបាយ ហើយបង្កើតបានជាមតិខ្វែងគ្នាទៅលើបញ្ហានេះ ។ បើក្រឡេកមើលប្រទេសដែលជាប្រភពដើមនៃការផ្សព្វផ្សាយសាសនាព្រះពុទ្ធ គឺប្រទេសស្រីលង្កានោះ ព្រះសង្ឃមានសិទ្ធិគាំទ្រ និងចូលរួមបម្រើសកម្មភាពរបស់គណបក្សនយោបាយ និងអាចឈរឈ្មោះជាបេក្ខជនរបស់គណបក្សនយោបាយផងដែរ ។

ទោះបីជាយ៉ាងណាក៏ដោយ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានផ្ដល់សិទ្ធិបោះឆ្នោតដល់ប្រជាពលរដ្ឋដោយមិនមានធ្វើការបែងចែករវាងអ្នកបោះឆ្នោតជាគ្រហស្ថពីអ្នកបោះឆ្នោតជាព្រះសង្ឃឡើយ ។ ការអនុវត្តសិទ្ធិបោះឆ្នោតរបស់បុព្វជិតសាសនា មិនមែនមានន័យថា បានភ្ជាប់ខ្លួនទៅបម្រើ ឬចូលរួមសកម្មភាពរបស់គណបក្សនយោបាយនោះទេ ប៉ុន្តែវាមានន័យថា ចូលរួមបញ្ចេញឆន្ទៈនយោបាយតាមការពេញចិត្តប៉ុណ្ណោះ ។ មានការសិក្សាច្រើនបានរកឃើញថា ព្រះពុទ្ធសាសនា ក៏ដូចជាចលនាពុទ្ធនិយម មានលក្ខណៈស្រប និងគាំទ្រគោលការណ៍ប្រជាធិបតេយ្យពិសេសការបោះឆ្នោតដោយយុត្តិធម៌ ។[១]

សេចក្ដីថ្លែងការណ៍រួមស្ដីពីតួនាទីសាសនាក្នុងការលើកស្ទួយវប្បធម៌ និងសន្តិភាព ខែធ្នូឆ្នាំ ១៩៩៤ បានស្នើថា *"សាសនាមិនត្រូវកំណត់ (អត្តសញ្ញាណ) ខ្លួនឯង ភ្ជាប់ជាមួយអំណាចនយោបាយ... របបនយោបាយអាចធ្វើឱ្យមានគ្រោះថ្នាក់ចំពោះតម្លៃសាសនា"*។ ក្នុងន័យនេះផងដែរ ច្បាប់បោះឆ្នោត និងច្បាប់គណបក្សនយោបាយនៅកម្ពុជា ក៏បានហាមឃាត់ថា *"បុព្វជិតមិនត្រូវបានអនុញ្ញាតធ្វើជាបេក្ខជន និងមិនត្រូវធ្វើសកម្មភាពគាំទ្រ ឬប្រឆាំងគណបក្សនយោបាយណាមួយឡើយ ។ គណបក្សក៏មិនត្រូវរៀបចំរចនាសម្ព័ន្ធចាត់តាំងក្នុងស្ថាប័នសាសនា"*។ ប៉ុន្តែ សម្រាប់ការអនុវត្តជាក់ស្ដែងនៅកម្ពុជា ឥទ្ធិពលគណបក្សនយោបាយបានគ្របដណ្ដប់ទៅលើវត្តអារាម និងព្រះសង្ឃ ។ ការសង្កេតឃើញថា ថ្នាក់ដឹកនាំព្រះសង្ឃចាប់ពីវត្តរហូតដល់ខេត្តមួយចំនួន សុទ្ធតែមានទំនាក់ទំនងយ៉ាងជិតស្និទ្ធិជាមួយអ្នកនយោបាយ ពិសេសមកពីគណបក្សកាន់អំណាច ។

រវាងការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ទាំងពីរលើកនេះ អ្វីដែលជាការផ្លាស់ប្ដូរគួរឱ្យចាប់អារម្មណ៍នោះគឺសង្ឃ ប្រកាសរបស់គណៈមេដឹកនាំសង្ឃ ។ នៅឆ្នាំ ២០០២ ព្រះសង្ឃសរុបមានចំនួន ៥៣.៨៦៩អង្គ ហើយសង្ឃប្រកាស ថ្ងៃទី ១៥ មិថុនា ២០០២ បានហាមឃាត់ព្រះសង្ឃមិនឱ្យចូលរួមការបោះឆ្នោត ហើយក្រោយមកទៀត

---

[១] Declaration on the Role of Religion on the Promotion of a Culture of Peace, organized by UNESCO, 1994.

មានការហាមឃាត់មិនឱ្យយកវត្តសម្រាប់ជាកន្លែងធ្វើវេទិកានានារបស់អង្គការមិនមែនរដ្ឋាភិបាល ដែលស្របនឹងយោបល់របស់នាយករដ្ឋមន្ត្រី។ ប៉ុន្តែសម្រាប់ការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់នៅថ្ងៃអាទិត្យ ទី០១ ខែមេសា ឆ្នាំ២០០៧ ខាងមុខនេះ ព្រះសង្ឃត្រូវបានអនុញ្ញាតឱ្យចូលរួមការបោះឆ្នោតវិញ តាមរយៈសង្ឃប្រកាស កាលពីថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០០៦ របស់សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតីសម្តេច ព្រះមហាសង្ឃរាជ។

មានឥទ្ធិពលនយោបាយទៅលើព្រះសង្ឃ និងវត្ត។ នៅក្នុងនោះ សម្រាប់ការសម្រេចនៅឆ្នាំ ២០០២ មានការរកឃើញថា ព្រះសង្ឃនៅថ្នាក់ក្រោមមួយចំនួនមានគំនិតតិះទៀនគណបក្សកាន់អំណាច និងរដ្ឋអំណាចជារឿយៗ ដែលបង្ហាញឡើងតាមរយៈឧទាហរណ៍មួយអំពីព្រឹត្តិការណ៍ចូលរួមបាតុកម្មជាចំហរបស់ព្រះសង្ឃប្រឆាំងនឹងលទ្ធផលនៃការបោះឆ្នោតឆ្នាំ ១៩៩៨ រហូតដល់មានការស្លាប់ និងរងរបួស ហើយបានបង្កើតភាពតានតឹងរវាងសាសនាព្រះសង្ឃ និងនយោបាយ។

អ្នកនយោបាយបានទំនាក់ទំនងជាមួយវត្ត និងសង្ឃល្បីៗ ដើម្បីទទួលបានបារមីនយោបាយ ហើយវត្តក៏ចង់បានជំនួយពីអ្នកនយោបាយ។ ការស្រាវជ្រាវមួយ[២] បានបង្ហាញថា *"ទោះបីយ៉ាងណា វត្តទាំងនេះមានការទាក់ទងជាមួយនឹងបរិយាកាសនយោបាយនៅអំឡុងពេលយុទ្ធនាការឃោសនាបោះឆ្នោតពីរលើកកន្លងមក។ ដោយឡែក អ្នកនយោបាយទៅវត្តអារាម ដើម្បីបរិចាគលុយ និងចំណីអាហារដល់ព្រះសង្ឃ និងដើម្បីបន់ស្រន់ស្វែងរកការជួយពីព្រះពុទ្ធ ដើម្បីសម្រេចគោលដៅរបស់ខ្លួន"*។ ជាងនេះទៅទៀត ព្រះសង្ឃជាចៅអធិការវត្តមួយ ដែលមិនបញ្ចេញឈ្មោះ បានមានសង្ឃដីកាថា *"ព្រះសង្ឃទទួលការបរិចាគពីប្រជាជនដែលមានឆន្ទៈល្អ។ យើងគ្រាន់តែទទួលការបរិចាគ យើងមិនបដិសេធការបរិចាគទាំងនោះទេ ទោះបីជាការបរិចាគទាំងនោះ ទទួលបានមកដោយអំពើហិង្សា [ឬអំពើពុករលួយ] ក៏ដោយ។ ... ការបរិចាគដូច្នេះ នឹងរំលត់ឥទ្ធិពលនៃអំពើបាបពីអតីតកាល ហើយបង្កើតជាកុសលល្អ ប៉ុន្តែមិនបាន ១០០% ដូចដែលគាត់រកលុយបានដោយខ្លួនឯងនោះទេ។"*

សម្រាប់ការប្រែប្រួលថ្មីៗនេះ ការសង្កេតឃើញថា គណបក្សកាន់អំណាច តាមរយៈអ្នកនយោបាយ និងមន្ត្រីរបស់ខ្លួនបានកំពុងប្រើប្រាស់អំណោយ និងជំនួយក្នុងការជួសជុលកសាងវត្តនានា ដើម្បីមានឥទ្ធិពល និងការត្រួតត្រានយោបាយទៅលើវត្តអារាមជាច្រើន។ មួយវិញទៀត កន្លងទៅនេះ ថែមទាំងមានការតែងតាំងប្រធានកងអង្គរក្សផ្ទាល់ (ផ្នែកកម្លាំងប្រដាប់អាវុធ) របស់សម្តេចនាយករដ្ឋមន្ត្រី ឱ្យធ្វើជាទីប្រឹក្សាសម្តេចព្រះសង្ឃរាជកាន់ការងារធម៌វិន័យ និងដោះស្រាយទំនាស់ក្នុងផ្នែកធម្មការ និងសាសនាទៅវិញ។

សម្តេចព្រះសង្ឃរាជ ទេព វង្ស ព្រះអង្គធ្លាប់ជាសមាជិកកណ្តាលមជ្ឈិមបក្សប្រជាជនកម្ពុជានៃរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា ហើយទើបត្រូវបានតែងតាំងជាសម្តេចព្រះ"មហា"សង្ឃរាជ នាពេលកន្លងទៅមិនជាយូរប៉ុន្មាន។ ពេលថ្មីៗកន្លងមកនេះដែរ សម្តេចព្រះមហាសង្ឃរាជមានសង្ឃដីកាខាងនយោបាយថា *"គណបក្សប្រជាជនកម្ពុជាជាគណបក្សម្ចាស់ផ្ទះ ឯគណបក្សផ្សេងទៀត ជាគណបក្សភ្ញៀវ"* ។ សង្ឃដីកាដូច្នេះ បានធ្វើឱ្យមានប្រតិកម្ម

[២] "People and the 1998 National Elections in Cambodia: Their Voices, Roles and Impact on Democracy", ECR, January 2002.

ភ្លាមៗពីសំណាក់ឯកឧត្តម សឺន សូប៊ែរ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ និងប្រធានមូលនិធិសម្តេច សឺន សាន ថា *"ខ្ញុំជឿថា សម្តេចព្រះមហាសង្ឃរាជ ទេព វង្ស មិនមែនជាសាវ័ករបស់ព្រះពុទ្ធជាម្ចាស់ឡើយ... នៅពេលនិយាយថា គណបក្សនយោបាយត្រូវបានចែកចេញជាពីរក្រុមដូច្នេះ ។"*[៣]

យោងតាមការសិក្សាសាកល្បងជាបឋមមួយ ដោយក្រុមការងារ អង្គការខុមហ្វ្រែលឱ្យដឹងថា ព្រះសង្ឃមួយចំនួនមិនទាន់ចាប់អារម្មណ៍នឹងសិទ្ធិនិមន្តចូលរួមបោះឆ្នោត ហើយមានតែព្រះសង្ឃភាគតិចបំផុតដែលចាប់អារម្មណ៍នឹងសង្ឃប្រកាសនេះ។ នេះអាចបណ្តាលមកពីការផ្សព្វផ្សាយសិទ្ធិបោះឆ្នោត និងសារសំខាន់នៃការបោះឆ្នោតដល់ព្រះសង្ឃ នៅមានកម្រិត។

យោងតាមរបាយការណ៏របស់ក្រសួងធម្មការ និងសាសនា ប្រទេសកម្ពុជាបច្ចុប្បន្ន មានព្រះសង្ឃចំនួនសរុប ៥៧.៥០៦អង្គ ក្នុងនោះព្រះសង្ឃនៃគណៈមហានិកាយមានចំនួន ៥៦.១៩៤អង្គ និងគណៈធម្មយុត្តិមានចំនួន ១.៣១២ អង្គ ដែលគង់នៅតាមវត្តសរុបចំនួន ៤.១៣៥។

នៅកម្ពុជា ព្រះសង្ឃគួរមិនត្រឹមតែប្រើប្រាស់សិទ្ធិបោះឆ្នោតប៉ុណ្ណោះទេ ប៉ុន្តែព្រះសង្ឃគួរថែមទាំងចូលរួមក្នុងចលនាលើកស្ទួយសិទ្ធិបោះឆ្នោតដល់ប្រជាពលរដ្ឋផងដែរ ដូចជាអាចចូលរួមក្នុងការងារផ្សព្វផ្សាយព័ត៌មានបោះឆ្នោត និងការយល់ដឹងអំពីការបោះឆ្នោតជាដើម។ សូមបញ្ជាក់ថា កន្លងមក ព្រះសង្ឃក៏បានចូលរួមក្នុងការធានាឱ្យមានបរិយាកាសអព្យាក្រឹតក្នុងដំណាក់កាលបោះឆ្នោត ដូចជាការចាប់ឆ្នោតជ្រើសរើសគណបក្សដាក់លេខរៀងក្នុងសន្លឹកឆ្នោតជាដើម។ ព្រះតេជគុណ ព្រះភិក្ខុសង្ឃ យូ ហុត ខេមចារោ មានសង្ឃដីកាថា[៤] *"...សាសនាបម្រើផលប្រយោជន៏ទូទៅ ជាកណ្តាល មិនលម្អៀង ជាអព្យាក្រិត ធ្វើសកម្មភាពទេសនា ពន្យល់ ផ្តល់យោបល់ ដាស់តឿន រំលឹក ណែនាំ អប់រំ មនុស្សទាំងអស់ក្នុងសង្គមឱ្យរៀនរស់នៅតាមគន្លងធម៌ ឱ្យប្រកបដោយធម៌ ទាំងជីវិតរស់នៅឯកជន ទាំងជីវិតរស់នៅសាធារណៈ ជីវិតនយោបាយ សេដ្ឋកិច្ច សង្គមកិច្ចទាំងអស់ ឱ្យអ្វីៗប្រព្រឹត្តទៅប្រកបដោយធម៌... ហើយស្ថាប័នសាសនា ព្រះសង្ឃសាមណៈ ដែលអាចបំពេញមុខងារនេះឱ្យបានល្អ ទាល់តែនៅអព្យាក្រិត នៅកណ្តាល មិនលម្អៀង នៅឱ្យឯករាជ្យ ក្នុងសេរីភាពពីអំណាចនយោបាយ អំណាចសេដ្ឋកិច្ច អំណាចសង្គម អំណាចទ្រព្យធនទាំងអស់ ដើម្បីលោកធ្វើការបម្រើយុត្តិធម៌ ធ្វើការដើម្បីសន្តិភាពពិតប្រាកដមែនបាន... នេះជាគោលការណ៏ទូទៅ។"*

**ខុមហ្វ្រែល អ្នកឃ្លាំមើល ថ្ងៃ ពុធ ទី ១៤ ខែកុម្ភៈ ឆ្នាំ២០០៧**

---

[៣] បកប្រែចេញពីកាសែតភ្នំពេញប៉ុស្តិ៍ : "Son Soubert takes issue with Great Supreme Patriarch", Phnom Penh Post, Issue 16 / 01, January 12 - 25, 2007.

[៤] សង្ឃដីកា នៅក្នុងការផ្សាយសំឡេងសង្គមស៊ីវិល នៅថ្ងៃទី ០២ កុម្ភៈ ២០០៧។